# ការណែនាំខ្លីៗ ពីការអនុវត្តន៍ពិធីសារបន្ថែមនៃអនុសញ្ញាអន្តរជាតិ ស្តីពីការលុបបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ
# (OP-CEDAW)

UNITED NATIONS
HUMAN RIGHTS
OFFICE OF THE HIGH COMMISSIONER
Cambodia

រាជរដ្ឋាភិបាលកម្ពុជាគឺជារដ្ឋភាគីនៃពិធីសារបន្ថែមលើអនុសញ្ញាស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ(OP-CEDAW)តាមរយៈការផ្តល់សច្ចាប័នលើពិធីសារនេះ។

ខិត្តប័ណ្ណនេះ បង្ហាញពីការណែនាំខ្លីៗ ជាជំហានៗ ដល់ក្រុមឬបុគ្គលណា ដែលមានបំណងដាក់ពាក្យបណ្តឹង ទៅគណៈកម្មាធិការ ស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ។

## ជំហានទី១៖ តើអ្នកមាន សិទ្ធិដាក់ពាក្យបណ្តឹងទៅគណៈកម្មាធិការនេះឬទេ?

**សូមពិនិត្យនូវចំណុចដូចខាងក្រោម៖**

- ✓ **ឈ្មោះ**របស់អ្នកត្រូវតែមានសរសេរនៅក្នុងពាក្យបណ្តឹង (មានន័យថា មិនត្រូវគ្មានឈ្មោះ ឬធ្វើដោយអនាមិក) នោះទេ។
- ✓ ប្រសិនជាអ្នក ធ្វើ**ជាតំណាង**ឲ្យអ្នកដទៃ អ្នកត្រូវតែមាន**ការយល់ព្រម**ជាលាយលក្ខណ៍អក្សរពីអ្នកនោះ ឬអ្នកត្រូវមាន**ហេតុផលសមស្រប** ដើម្បីប្តឹងទាមទារជំនួសគាត់។
- ✓ អ្នកត្រូវដាក់ពាក្យបណ្តឹង**ជាលាយលក្ខណ៍អក្សរ**។
- ✓ អ្នក ឬបុគ្គលដែលអ្នកធ្វើជាតំណាងឲ្យនោះ ទទួលរងនូវ**ការបំពាន** ក្រោមបញ្ញត្តិនៃអនុសញ្ញានេះ។
- ✓ ការរំលោភបំពាននេះ បានកើតឡើង នៅក្រោយពេលដែលពិធីសារបន្ថែមលើអនុសញ្ញានេះ ចូលជាធរមាននៅកម្ពុជាកាលពីថ្ងៃទី១២-១-២០១១ ឬក៏ការបំពាននោះ កើតឡើងមុនការផ្តល់សច្ចាប័ន តែនៅបន្តរហូតដល់ក្រោយការផ្តល់សច្ចាប័ន។

## ជំហានទី២៖ តើពាក្យបណ្តឹងរបស់អ្នក ត្រូវយកមកពិនិត្យពិចារណាដែរឬទេ?

**សូមពិនិត្យនូវចំណុចដូចខាងក្រោម៖**

- ✓ អ្នកបាន**ប្រើប្រាស់អស់ហើយ នូវដំណោះស្រាយទាំងអស់ ដែលលោកអ្នកមាននៅក្នុងប្រទេស** ក្នុងការដោះស្រាយការបំពាននេះ។
- ✓ អ្នកបានរង់ចាំក្នុងរយៈពេលមួយ**សមល្មម**ហើយ ដើម្បីឲ្យ មានការពិនិត្យពិចារណាលើបណ្តឹងរបស់អ្នក នៅក្នុងប្រព័ន្ធច្បាប់ជាតិ និងដើម្បីឲ្យទទួលបាន**ដំណោះស្រាយមួយមានប្រសិទ្ធភាព**។
- ✓ ពាក្យបណ្តឹងរបស់អ្នក ត្រូវស្ថិតនៅក្រោមវិសាលភាពនៃអនុសញ្ញានេះ ហើយត្រូវ**មានហេតុផលសមស្រប**សំរាប់ការប្តឹងទាមទារសិទ្ធិរបស់អ្នក។
- ✓ **បណ្តឹង**របស់លោកអ្នក **មិនធ្លាប់ត្រូវបានច្រានចោលដោយ** គណៈកម្មាធិការនេះ**ទេ**។
- ✓ បណ្តឹងរបស់អ្នក មិនត្រូវបាន**គណៈកម្មាធិការអន្តរជាតិណាមួយផ្សេងទៀត** កំពុង**ពិនិត្យពិចារណា**នោះទេនៅពេលដាក់បណ្តឹងនេះ។

## ជំហានទី៣៖ តើគួរបញ្ចូលព័ត៌មានអ្វីខ្លះ នៅក្នុងពាក្យបណ្តឹងរបស់អ្នក?

**សូមពិនិត្យនូវចំណុចសំខាន់ៗក្នុងពាក្យបណ្តឹងរបស់អ្នក៖**

- ✓ ពាក្យបណ្តឹង ត្រូវសរសេរជាភាសាណាមួយនៃភាសាផ្លូវការរបស់អង្គការសហប្រជាជាតិ (អារ៉ាប់ ចិន អង់គ្លេស បារាំង រុស្ស៊ី ឬអេស្ប៉ាញ)។
- ✓ បញ្ចូលព័ត៌មានផ្សេងៗអំពី**លោកអ្នក**។
- ✓ បញ្ចូលព័ត៌មានពីបុគ្គលណាមួយដែលអ្នកដាក់ពាក្យបណ្តឹងជំនួសគាត់ និងការយល់ព្រមជាលាយលក្ខណ៍អក្សរពីគេ។
- ✓ បញ្ចូលអង្គហេតុអំពីបណ្តឹង និងចរិតលក្ខណៈនៃការរំលោភបំពានដែលចោទប្រកាន់ (រាប់ទាំងការបរិយាយពីការរំលោភបំពាននោះ និងឈ្មោះជនដៃដល់ កាលបរិច្ឆេទ ទីកន្លែង និងពេលវេលានៃការប្រព្រឹត្ត ព្រមទាំងបទបញ្ញត្តិណានៃអនុសញ្ញាដែលត្រូវបានរំលោភបំពាន។
- ✓ បញ្ចូលព័ត៌មានពីវិធានការរបស់អ្នក ដែលបានប្រើប្រាស់អស់លទ្ធភាពដោះស្រាយតាមច្បាប់ជាតិ។
- ✓ បញ្ចូលព័ត៌មាន ពីការស្វែងរក ដំណោះស្រាយជាអន្តរជាតិដទៃទៀត ដែលអ្នកបានប្រើ។
- ✓ ទម្រង់គំរូបណ្តឹងអាចរកបាននៅគេហទំព័រ៖ www2.ohchr.org/english/law/cedaw-one.htm

## ជំហានទី៤៖ តើលោកអ្នក ត្រូវបញ្ជូនពាក្យបណ្តឹងរបស់អ្នកទៅកន្លែងណា?

លោកអ្នក ត្រូវបញ្ជូនពាក្យបណ្តឹងរបស់លោកអ្នកទៅ៖

គណៈកម្មាធិការស្តីពីការបំបាត់រាល់ទម្រង់នៃការរើសអើងប្រឆាំងនឹងស្ត្រីភេទ

ក្រុមទទួលញត្តិ ឬពាក្យបណ្តឹង

ការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្ស

ទីស្នាក់ការអង្គការសហប្រជាជាតិ នាទីក្រុងហ្សឺណែវ

១២១១ ហ្សឺណែវ ១០ ប្រទេសស្វីស

អ៊ីម៉ែល: tb-petitions@ohchr.org

ការដាក់ពាក្យបណ្តឹងនេះ អាចធ្វើបានតាមរយៈសារអេឡិចត្រូនិច។

លោកអ្នកក៏អាចទាក់ទងផ្ទាល់មកការិយាល័យឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៅកម្ពុជា សំរាប់ព័ត៌មានបន្ថែម។

## ជំហានទី៥៖ តើគណៈកម្មាធិការនេះ នឹងត្រូវធ្វើអ្វីខ្លះ?

**ដំបូងបង្អស់ គណៈកម្មាធិការនេះ** នឹងទាក់ទងទៅ**រដ្ឋាភិបាល**។ ក្នុងករណីដែលអ្នក បានធ្វើត្រឹមត្រូវតាមជំហានទី១ និងជំហានទី២ រួចហើយ គណៈកម្មាធិការនេះ៖

- ✓ **នឹង**ពាំនាំ**បណ្តឹងរបស់អ្នក ដោយសំងាត់ ឲ្យរដ្ឋាភិបាលកម្ពុជា**យកចិត្តទុកដាក់ និងអាច**ប្រាប់ពីឈ្មោះរបស់អ្នក**បាន លុះត្រាតែមានការយល់ព្រមពីអ្នក។
- ✓ **អាច**បញ្ជូន**សំណើមួយ** ទៅ**រដ្ឋាភិបាលកម្ពុជា** ស្នើសុំឲ្យចាត់**វិធានការបណ្តោះអាសន្ន** ដើម្បីបញ្ចៀសនូវការបំពានថែមទៀតដល់អ្នក នៅពេលដែលគណៈកម្មាធិការកំពុងពិនិត្យមើលអង្គហេតុនៃបណ្តឹងរបស់អ្នក។
- ✓ **នឹងស្នើសុំ**ឲ្យមានការឆ្លើយតបជាលាយលក្ខណ៍អក្សរពី**រដ្ឋាភិបាលកម្ពុជា** ក្នុងរយៈពេល**ប្រាំមួយខែ** គិតពីកាលបរិច្ឆេទ**ដែលគណៈកម្មាធិការ** បានបញ្ជូន**សំណើ**នេះចេញ។

**បន្ទាប់មក គណៈកម្មាធិការនេះ នឹងពិនិត្យលើព័ត៌មានដែលទទួលបាន**។ គណៈកម្មាធិការ នឹងពិនិត្យនៅក្នុងកិច្ចប្រជុំបិទទ្វារ។ ឯកសារនានាដែលគណៈកម្មាធិការបានទទួលពីអ្នក និងពី**រដ្ឋាភិបាលកម្ពុជា** រួមមាន៖

- ✓ របាយការណ៍នានារបស់អង្គការមិនមែនរដ្ឋាភិបាល។
- ✓ របាយការណ៍នានារបស់អង្គការសហប្រជាជាតិ។
- ✓ ការវិភាគអំពីច្បាប់ជាតិ ឬច្បាប់អន្តរជាតិ។
- ✓ ភស្តុតាងជាឯកសារបន្ថែម មានដូចជាចម្លើយកសិណសាក្សី (សក្ខីកម្ម) វីដេអូ រូបថត ជាដើម។
- ✓ ព័ត៌មានផ្សេងទៀតដែលអាចទុកចិត្តបាន ដែលបានផ្តល់ជូនគណៈកម្មាធិការនេះ។

លោកអ្នក គួរតែផ្តល់ភស្តុតាងជូនគណៈកម្មាធិការនេះ ឲ្យបានច្រើនតាមដែលអាចធ្វើទៅបាន ដើម្បីគាំទ្រដល់បណ្តឹងរបស់អ្នក!

**នៅចុងបញ្ចប់ គណៈកម្មាធិការនេះ នឹងបញ្ជូនការយល់ឃើញ (មតិយោបល់)និងអនុសាសន៍របស់ខ្លួនទៅភាគីទាំងពីរ គឺអ្នក និងរដ្ឋាភិបាលកម្ពុជា**។ គណៈកម្មាធិការ នឹងធ្វើការសន្និដ្ឋាន ថាតើមានការរំលោភបំពានបទបញ្ញត្តិនៃអនុសញ្ញាឬអត់។ បើមាន នឹងដាក់ស្នើនូវអនុសាសន៍នានា ដែលអាចរួមមានដូចខាងក្រោម៖

- ✓ ដំណោះស្រាយជាក់លាក់មួយចំនួន ចំពោះករណីរំលោភបំពានដែលបានលើកឡើងនេះ។
- ✓ ចាត់វិធានការមួយចំនួនដើម្បីបញ្ចប់ការរំលោភបំពានលើអ្នក។
- ✓ ការពិនិត្យឡើងវិញ ឬការកែប្រែច្បាប់មួយចំនួន ដើម្បីទប់ស្កាត់មិនឲ្យមានការរំលោភបំពានបែបនេះតទៅទៀត។

## ជំហានទី៦៖ តើរដ្ឋាភិបាលមានកាតព្វកិច្ចអ្វីខ្លះ ចំពោះអនុសាសន៍របស់គណៈកម្មាធិការនេះ?

រដ្ឋាភិបាលកម្ពុជាមានកាតព្វកិច្ចពិនិត្យពិចារណាឲ្យបានត្រឹមត្រូវចំពោះអនុសាសន៍របស់គណៈកម្មាធិការ។ ប្រសិនបើគណៈកម្មាធិការយល់ឃើញថា សមស្រប គណៈកម្មាធិការនឹងអញ្ជើញរដ្ឋាភិបាល ឲ្យផ្តល់ព័ត៌មានបន្ថែមអំពីការរំលោភបំពានដែលបានត្រូវចោទប្រកាន់នេះ និងអំពីវិធានការនានាដែលរដ្ឋាភិបាលបានធ្វើ ដើម្បីដោះស្រាយករណីនេះ។ រដ្ឋាភិបាល មិនជាប់កាតព្វកិច្ចផ្លូវច្បាប់ ចំពោះអនុសាសន៍របស់គណៈកម្មាធិការនេះទេ ក៏ប៉ុន្តែរដ្ឋាភិបាល គួរតែគោរពតាមអនុសាសន៍ទាំងនេះ៕

*OHCHR Cambodia: House No. 10, Street 302*
*Boeng Keng Kang I, Phnom Penh*
*Tel: 855-23-993 590/91     855-23-987 671/72*